ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ០០១ សរណន

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៥

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល លេខ: ៥៧០ ក.អ.ជ
ថ្ងៃទី ១៨.០៣.១៥ ម៉ោង ១០h០០mn
បញ្ជូន............

**សារាចរណែនាំ**

**ស្តីពី**

**ការបង្ការសកម្មភាពប្រើប្រាស់ និងការធ្វើអាជីវកម្មផលិតផលស៊ីសា (Shisha)**

**និង អ៊ី-ស៊ីហ្គាវ៉ែត (E-Cigarette) នៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍**

**យោង÷** អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាឱកាសកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារទេសចរណ៍ ២០១២-២០១៣ និងទិសដៅអនុវត្តបន្ត **"ទេសចរណ៍កម្ពុជាឆ្ពោះទៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥"** និងការអបអរសាទរទិវាជាតិទីក្រុងស្អាតឆ្នាំ២០១៤ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ នៅសាលបុរីកោះពេជ្រ។

ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ទាំង២៤ និងលោកឧកញ៉ា លោក លោកស្រីដែលជាម្ចាស់អាជីវកម្មទេសចរណ៍ទាំងអស់ឱ្យបានជ្រាប ដើម្បីជាការក្រើនរំឭក និងពង្រឹងបន្ថែមដល់សកម្មភាពបង្ការ និងទប់ស្កាត់ការប្រើប្រាស់ និងការធ្វើអាជីវកម្មផលិតផល**ស៊ីសា** (Shisha) **និងអ៊ីស៊ីហ្គាវ៉ែត** (E-Cigarette) នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ ដូចតទៅ:

១. គ្រប់អាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវមានអាជ្ញាប័ណ្ណទេសចរណ៍ដែលត្រូវមកស្នើសុំនៅក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

២. មន្ទីរទេសចរណ៍រាជធានី-ខេត្ត ទាំង២៤ ត្រូវចាត់វិធានការបន្ទាន់ស្រាវជ្រាវនៅតាមគ្រប់ទីតាំងអាជីវកម្មទេសចរណ៍ទាំងអស់ សំដៅធ្វើយ៉ាងណាបង្ការ និងទប់ស្កាត់ឱ្យបានជាអតិបរិមានូវការឆ្លៀតឱកាសប្រើប្រាស់ទីតាំងទាំងនោះជាកន្លែងជួញដូរផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គាវ៉ែត** (E-Cigarette)។

៣. មន្ទីរទេសចរណ៍រាជធានី-ខេត្ត ទាំង២៤ ត្រូវធ្វើការណែនាំ និងផ្សព្វផ្សាយដល់ទីតាំងអាជីវកម្មទេសចរណ៍ទាំងអស់អំពីផលប៉ះពាល់អំពីការជួញដូរផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គាវ៉ែត** (E-Cigarette) មកលើសង្គម វប្បធម៌ប្រពៃណីដ៏ល្អរបស់ខ្មែរ សុខភាព និងអនាគតរបស់យុវជន។ល។

៤. មន្ទីរទេសចរណ៍រាជធានី-ខេត្តទាំង ២៤ ត្រូវសហការជាមួយកម្លាំងសមត្ថកិច្ចចម្រុះចុះធ្វើកិច្ចសន្យាជាមួយអាជីវកម្មទេសចរណ៍ទាំងឡាយណាដែលបាននឹងកំពុងផ្តល់សេវា ឬផ្តល់ទីតាំងឱ្យប្រើប្រាស់ផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គាវ៉ែត** (E-Cigarette) ឱ្យឈប់បន្តសកម្មភាពទាំងនេះ។

៥. មន្ទីរទេសចរណ៍រាជធានី-ខេត្ត ទាំង២៤ ត្រូវស្នើសុំការសហការពីអង្គភាពមានសមត្ថកិច្ចចុះដកហូតផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គាវ៉ែត** (E-Cigarette) និងសារធាតុប្រហាក់ប្រហែល ព្រមទាំងសម្ភារៈសំរាប់

ប្រើប្រាស់ជក់ ឬស្រូបសារធាតុទាំងនោះនៅតាមទីតាំងអាជីវកម្មទេសចរណ៍ដែលមានស្របតាមនីតិវិធីដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តជាធរមាន។ នឹងអាចឈានទៅដល់ការ ព្យួរអាជ្ញាបណ្ណ ឬដកហូតអាជ្ញាបណ្ណទេសចរណ៍ស្របតាមនីតិវិធីដែលមានកំណត់ក្នុងបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីមិនរាងចាល។

៦. ម្ចាស់អាជីវកម្ម ត្រូវចូលរួមទប់ស្កាត់ និងបង្ការការប្រើប្រាស់ និងធ្វើអាជីវកម្មផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គារ៉ែត** (E-Cigarette) តាមរយៈ៖

- មិនត្រូវផ្តត់ផ្គង់សេវា ឬអនុញ្ញាតិឱ្យប្រើប្រាស់ទីតាំងអាជីវកម្មរបស់ខ្លួនជាកន្លែងជួញដូរ ឬប្រើប្រាស់ផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គារ៉ែត** (E-Cigarette)
- ត្រូវសហការឱ្យមានប្រសិទ្ធិភាពជាមួយកងកម្លាំងសមត្ថកិច្ចចម្រុះក្នុងករណីមានសកម្មភាពបង្ក្រាប ឬបង្ការការជួញដូរ និងប្រើប្រាស់ផលិតផល **ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គារ៉ែត** (E-Cigarette)
- ត្រូវជូនដំណឹងទៅសមត្ថកិច្ចក្នុងករណីមានសកម្មភាពការជួញដូរ និងប្រើប្រាស់ផលិតផល**ស៊ីសា** (Shisha) និង **អ៊ី-ស៊ីហ្គារ៉ែត** (E-Cigarette) នៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គភាពមានសមត្ថកិច្ចអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ និងធ្វើរបាយការណ៍ជាប្រចាំមកក្រសួងទេសចរណ៍អំពីវឌ្ឍនភាពការងារនេះសំដៅធ្វើយ៉ាងណាធានាឱ្យបាននូវការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តភាព។

រដ្ឋមន្ត្រី

ថោង ខុន

**<u>កន្លែងទទួល៖</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
  "ដើម្បីជម្រាបជូន"
- គ្រប់មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីមុខការ"
- គ្រប់អាជីវកម្មទេសចរណ៍
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ